**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍
# ប្រជុំរួមប្រចាំខែឧសភា ឆ្នាំ ២០១៥

នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោង០៩:០០នាទីព្រឹក នៅអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំមន្ត្រីរាជការ បុគ្គលិកទាំងអស់ប្រចាំខែឧសភា ឆ្នាំ២០១៥ និង រៀបចំពិធីផ្ទេរតំណែងប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និង ស្រាវជ្រាវ ដែលដឹកនាំការប្រជុំដោយ **ឯកឧត្តមវេជ្ជ. តែង គន្ធី** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះ មាន៖ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ និង មន្ត្រីរាជការ បុគ្គលិកទាំងអស់ ចំនួន ៦០ នាក់ ។

**អវត្តមាន**

១- លោកវេជ្ជ. អ៊ុក ម៉ារឌី — អនុប្រធាននាយកដ្ឋាន PCS

២- លោកវេជ្ជ. នុត សុភាព — អនុប្រធានការិយាល័យ នាយកដ្ឋាន CRM ( ច្បាប់ )

គោលបំណងនៃកិច្ចប្រជុំនេះ មាន៖

- ពិធីផ្ទេរតំណែងប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និង ស្រាវជ្រាវ
- កិច្ចប្រជុំរួមប្រចាំខែ
  1. ការងាររដ្ឋបាល
     - ស្ថានភាពបុគ្គលិក
     - ពង្រឹងវិន័យ និង របៀបរបបធ្វើការងាររបស់មន្ត្រីរាជការ
  2. ការងារផ្សេងៗ ( មន្ត្រីមានយោបល់ )

ជាកិច្ចចាប់ផ្តើម ឯកឧត្តមអគ្គលេខាធិការ មានមតិស្វាគមន៍ និង ថ្លែងអំណរគុណដល់មន្ត្រីដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនេះ និង មានការកោតសរសើរ ដែលបានគោរពវិន័យបានល្អប្រសើរ ។

**ពិធីផ្ទេរតំណែងប្រធាននាយកដ្ឋាន ត្រួតពិនិត្យ តាមដាន វាយតម្លៃ និង ស្រាវជ្រាវ**

ឯកឧត្តម **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការរង អានអនុក្រឹត្យស្តីពីការតែងតាំងប្រធាននាយដ្ឋានថ្មី ។

លោកស្រី វេជ្ជ. ជិន លីណា អតីតប្រធាននាយដ្ឋានត្រួតពិនិត្យ តាមដាន វាយតម្លៃ និង ស្រាវជ្រាវ បង្ហាញអំពីប្រវត្តិចូលធ្វើការនៅក្នុងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

សំណូមពរ

- ធ្វើការងារទៅតាមប្រព័ន្ធ និង ទៅតាមឋានុក្រម តួនាទី ។
- មន្ត្រីថ្នាក់ក្រោម ត្រូវគិតគូដោយខ្លួនឯង ហើយធ្វើការងារជាលក្ខណៈគ្រួសារ ដើម្បីភាពរីកចំរើនរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

លោកវេជ្ជ. រស់ សីលវ៉ាត់ អគ្គលេខាធិការរង និង ជាប្រធាននាយដ្ឋានថ្មី បានមានមតិ

- ថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំដែលមានទំនុកចិត្ត ផ្តល់ការងារនេះ ។
- មានភាពជោគជ័យច្រើន ក្នុងការងារដែលនាយកដ្ឋាននេះបានអនុវត្តន៍កន្លងមក ។
- សូមអោយមានការគាំទ្រខ្ញុំបាទ ដើម្បីរួមចំណែកធ្វើការងារទទួលបានជោគជ័យទាំងអស់គ្នា ។
- សូមនាយកដ្ឋានផ្សេងៗទៀតរួមសហការគ្នាដើម្បីភាពជោគជ័យក្នុងការងារ។
- សូមសន្យា តាំងចិត្ត ព្យាយាម ធ្វើឱ្យសំរេចបាន នូវការងារសម្រាប់ជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

**មតិផ្តាំផ្ញើរបស់ឯកឧត្តមអគ្គលេខាធិការ**

- ពិធីនេះធ្វើឡើងសម្រាប់បង្ហាញអំពីការយកចិត្តទុកដាក់ សាមគ្គីភាព ។
- សូមថ្លែងអំណរគុណ ដែលលោកស្រីបានខិតខំ និង ចំណាយពេលវេលាទាំងកំលាំងកាយ និង កំលាំងចិត្ត ដើម្បីសំរេចបាននូវការងារធំៗ ជាច្រើនជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- សូមលើកទឹកចិត្តទាំងប្រធាននាយកដ្ឋានចាស់ និង ប្រធាននាយកដ្ឋានថ្មី តាមរយៈបទពិសោធន៍នេះ អ្នកនឹងក្លាយទៅជាអ្នកដឹកនាំដ៏ល្អមួយនាពេលអនាគត ។

- សូមឱ្យប្រធាននាយកដ្ឋានត្រួតពិនិត្យ តាមដាន វាយតម្លៃ និង ស្រាវជ្រាវថ្មីទំនាក់ទំនងបន្តទៅទៀត ដើម្បីទទួលបានជោគជ័យ ។
- ស្នើឱ្យប្រធាននាយកដ្ឋានត្រួតពិនិត្យ តាមដាន វាយតម្លៃ និង ស្រាវជ្រាវថ្មី ត្រូវស្វែងយល់ពីស្ថានភាពការងារ ស្ថានភាពមន្ត្រី បុគ្គលិកក្រោមឱវាទ ដើម្បីភាពជោគជ័យការងារ និងចេះផ្តល់ឱកាសឲ្យគ្នាទៅវិញទៅមក ។

- ប៉ុន្តែអ្នកទាំងអស់ត្រូវយល់ថ្ងៃនេះ គឺជាកិច្ចប្រជុំរួមប្រចាំខែ ដូចនេះ អវត្តមាន មានតម្លៃ និង បានការ ចំពោះមន្ត្រីរាជការស៊ីវិល ។ ភាពបត់បែន របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់ត្រូវស្វែងយល់ដោយខ្លួនឯង ។
- សូមបន្តសកម្មភាព តាមរយៈការតស៊ូមតិ និង ការតាំងចិត្តទទួលយកជោគជ័យនូវការប៉ងប្រាថ្នារបស់យើង ។

**កម្មវិធីប្រជុំប្រចាំខែឧសភា ឆ្នាំ២០១៥**

**ឯកឧត្តមអគ្គលេខាធិការ មានមតិបូកសរុប**

- កិច្ចប្រជុំរួមត្រូវប្រជុំចាប់ផ្តើមពីម៉ោង ០៩:០០នាទីព្រឹកជាកំណត់ ។ ដូចនេះ មន្ត្រីទាំងអស់ ត្រូវគោរពវិន័យ ហើយយើងម្នាក់ៗ ត្រូវឱ្យតម្លៃលើខ្លួនឯង ។
- គ្រប់ប្រធាននាយកដ្ឋាន មុនបញ្ជូនលិខិតចុះបេសកកម្ម ឬ លិខិតផ្សេងៗ ត្រូវផ្តល់តម្លៃខ្លួនឯង នូវការចុះហត្ថលេខារបស់ខ្លួន ។
- ថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៥ មានពិធីធំៗ ស្នើឱ្យនាយកដ្ឋានដែលពាក់ព័ន្ធ ត្រូវពង្រឹងផ្នែកបច្ចេកទេស និង រដ្ឋបាលក្នុងការរៀបចំពិធីនេះ ។
- រាល់លិខិតទាំងអស់ ដែលចេញពីនាយកដ្ឋាន ត្រូវពិនិត្យរាល់ លិខិតទាំងនោះ ឱ្យបានច្បាស់លាស់ ។
- ស្នើនាយកដ្ឋានទាក់ទង និង ចលនាប្រភពធនធាន រៀបចំរបៀបវារៈ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅក្នុងសប្តាហ៍នេះ ហើយត្រូវដឹកនាំកិច្ចប្រជុំជាមួយ ស្តីពីគោលការណ៍ណែនាំពីការផ្តល់ថវិកាតាមខេត្ត ។

ជាចុងក្រោយ ឯកឧត្តមអគ្គលេខាធិការ បានកោតសរសើរមន្ត្រី បុគ្គលិកទាំងអស់ ខិតខំប្រឹងប្រែងទាំងអស់គ្នា ក្នុងការអនុវត្តន៍ការងារឲ្យបានល្អប្រសើរ ប្រកបដោយសាមគ្គីភាព ចេះជួយគ្នាទៅវិញទៅមក និង សុំបន្តនូវប្រពៃណីសាមគ្គីភាពគ្នាតទៅទៀត ។ ត្រូវផ្តល់មតិយោបល់គ្នា ក្នុងនាមជាគ្រួសារមិត្តភ័ក្តរួមការងារ ។

អង្គប្រជុំបានបញ្ចប់ នៅវេលាម៉ោង ១១:០០នាទី នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយក្រៃលែង៕

**អ្នកធ្វើរបាយការណ៍**

បានឃើញ និង ឯកភាព

ប្រធានអង្គប្រជុំ

ហ៊ុន ស